**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេស ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅ៖

- សម្រិតសម្រាំងសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ
- លើកទឹកចិត្តសិស្សនៅមធ្យមសិក្សាឱ្យផ្តោតការយកចិត្តទុកដាក់លើអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ
- ផ្តល់តម្លៃដល់ជ័យលាភីសិស្សពូកែ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជ័យលាភីសិស្សពូកែទូទាំងប្រទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណោះទូទៅសាធារណៈនិងឯកជនថ្នាក់ទី៩និងថ្នាក់ទី១២។

## ជំពូកទី២

## ការប្រឡងជ្រើសរើសសិស្សពូកែ

**មាត្រា៤ .-**

ការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្តផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ថ្នាក់ទី៩ និងថ្នាក់ទី១២ ត្រូវរៀបចំឡើងដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ថ្នាក់ទី៩ និងថ្នាក់ទី១២ត្រូវរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

យន្តការនិងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្តថ្នាក់ទី៩ និងថ្នាក់ទី១២ និងយន្តការនិងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩និងថ្នាក់ទី១២ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩និងថ្នាក់ទី១២ ត្រូវប្រព្រឹត្តទៅនៅរាជធានីភ្នំពេញឬទីរួមខេត្តណាមួយ ទាំងដំណើរការសំណេរ កំណែ ស្រង់ បូកពិន្ទុនិងប្រកាសលទ្ធផលប្រឡង។

វិញ្ញាសាប្រឡងត្រូវចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ សម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី៩ និងផ្អែកលើកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី១២ សម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសថ្នាក់ទី១២។

**មាត្រា៧ .-**

ក្នុងការប្រឡងជ្រើសរើសសិស្សពូកែតាមឆ្នាំសិក្សានីមួយៗ បេក្ខជនម្នាក់ៗមានសិទ្ធិជ្រើសរើសបានតែមួយមុខវិជ្ជាគត់ក្នុងចំណោមមុខវិជ្ជាទាំងបី។

**មាត្រា៨ .-**

គណៈមេប្រយោគប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ត្រូវបំពេញការងារតាមចំនួនថ្ងៃជាក់ស្តែង និងទទួលប្រាក់ឧបត្ថម្ភតាមរបបម៉ោងបន្ថែមដោយគិតក្នុងមួយថ្ងៃបំពេញការងារ៦(ប្រាំមួយ)ម៉ោងបន្ថែម ហើយប្រាក់កំរៃមួយម៉ោងបន្ថែមស្មើប្រាក់កម្រៃនៃមួយម៉ោងបន្ថែមរបស់គ្រូមធ្យមសិក្សាទុតិយភូមិ។

ការចាត់តាំងគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗសម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ជាសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៩ .-**

ថវិកាប្រឡងសម្រាប់ចំណាយលើសម្ភារៈចាំបាច់ផ្សេងៗ ការរៀបចំពិធីបើកការប្រឡង និងពិធីចែករង្វាន់ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុករបស់ប្រតិភូរាជធានី ខេត្ត និងបេក្ខជន និងចំណាយសម្រាប់រៀបចំដំណើរកម្សាន្តរបស់បេក្ខជន ជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣

## រង្វាន់និងការលើកទឹកចិត្ត

**មាត្រា១០ .-**

ជ័យលាភីសិស្សពូកែទូទាំងប្រទេស ត្រូវទទួលបានរង្វាន់និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាលដូចខាងក្រោម៖

១. ប្រកាសស្តីពីការទទួលស្គាល់សិស្សពូកែ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មួយច្បាប់

២. មេដាយមួយគ្រឿង សម្រាប់បេក្ខជនជ័យលាភីចំណាត់ថ្នាក់ពីលេខ១ដល់លេខ៣

៣. វិញ្ញាបនបត្របញ្ជាក់សិស្សពូកែទូទាំងប្រទេស មួយច្បាប់

៤. ប្រាក់រង្វាន់តាមចំណាត់ថ្នាក់៖

- ចំណាត់ថ្នាក់លេខ១ ៣ ៥០០ ០០០ (បីលានប្រាំសែន)រៀល
- ចំណាត់ថ្នាក់លេខ២ ៣ ២០០ ០០០ (បីលានពីរសែន)រៀល
- ចំណាត់ថ្នាក់លេខ៣ ២ ៩០០ ០០០ (ពីរលានប្រាំបួនសែន)រៀល
- ចំណាត់ថ្នាក់លេខ៤ ២ ៦០០ ០០០ (ពីរលានប្រាំមួយសែន)រៀល
- ចំណាត់ថ្នាក់លេខ៥ ២ ៣០០ ០០០ (ពីរលានបីសែន)រៀល
- ចំណាត់ថ្នាក់លេខ៦ ២ ០០០ ០០០ (ពីរលាន)រៀល
- ចំណាត់ថ្នាក់លេខ៧ ១ ៧០០ ០០០ (មួយលានប្រាំពីរសែន)រៀល
- ចំណាត់ថ្នាក់លេខ៨ ១ ៤០០ ០០០ (មួយលានបួនសែន)រៀល
- ចំណាត់ថ្នាក់លេខ៩ ១ ១០០ ០០០ (មួយលានមួយសែន)រៀល
- ចំណាត់ថ្នាក់លេខ១០ ៨០០ ០០០ (ប្រាំបីសែន)រៀល

បុគ្គល បព្វជិត គ្រួសារ សហគមន៍ សង្គមស៊ីវិល ស្ថាប័នរដ្ឋនិងឯកជនទាំងអស់ មានសិទ្ធិផ្តល់រង្វាន់ជាសម្ភារៈ ឬថវិកាជូនជ័យលាភីសិស្សពូកែ។

**មាត្រា១១ .-**

ក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចរៀបចំពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស និងរៀបចំពិធីចែករង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ឱ្យបានសមរម្យ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ